01030088

E314/4/4

សាធារណៈ / Public

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 10 / 2014
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SAMRANG

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អនុស្សរណៈអន្តរការិយាល័យ - អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤

**ជូនចំពោះ:** គណៈកម្មាធិការរដ្ឋបាលតុលាការ

**ចម្លងជូន:** ភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២/០២

**ពី:** ចៅក្រម ធូ មណី ប្រធានក្រុមប្រឹក្សាជំនុំជម្រះពិសេស

**កម្មវត្ថុ:** សំណើសុំឲ្យមានការចាត់តាំងចៅក្រមក្នុងគោលបំណងដើម្បីជំនួសចៅក្រម ប៉ែន ពេជ្រសាលី

នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ គណៈកម្មាធិការរដ្ឋបាលតុលាការបានចាត់តាំងចៅក្រមដើម្បីបង្កើតបានជាក្រុមប្រឹក្សាជំនុំជម្រះពិសេស សម្រាប់ជំនុំជម្រះទៅលើបណ្តឹងជំទាស់នឹងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ (E314/1, E314/6) ។ ចៅក្រមនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះពិសេសនេះមានសមាសភាព៖ ចៅក្រម ធូ មណី (ប្រធាន), ចៅក្រម Rowan Downing, ចៅក្រម Chang-ho Chung, ចៅក្រម ប៉ែន ពេជ្រសាលី និងចៅក្រម ហួត វុទ្ធី (E314/4)។

កាលពីថ្ងៃ ០៦ ខែ តុលា ឆ្នាំ ២០១៤ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានទទួលបណ្តឹងជំទាស់របស់ នួន ជា សុំដកចៅក្រម ប៉ែន ពេជ្រសាលី ពីក្រុមប្រឹក្សាជំនុំជម្រះពិសេស (E314/4/1)។ នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ គណៈកម្មាធិការរដ្ឋបាលតុលាការបានចាត់តាំងចៅក្រម ប្រាក់ គឹមសាន ដើម្បីជំនួសចៅក្រម ប៉ែន ពេជ្រសាលី សម្រាប់ដោះស្រាយទៅលើបណ្តឹងជំទាស់របស់ក្រុមមេធាវីការពារក្តី នួន ជា ប្រឆាំងនឹងចៅក្រម ប៉ែន ពេជ្រសាលី (E314/4/3)។

នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានទទួលការជូនដំណឹងថា ចៅក្រម ប៉ែន ពេជ្រសាលី បានសម្រេចចិត្តដកខ្លួនចេញពីក្រុមប្រឹក្សាជំនុំជម្រះពិសេស។

យោងតាមវិធាន៣៤(៦) នៃវិធានផ្ទៃក្នុង នៅពេលដែលមានបណ្ដឹងជំទាស់ "ចៅក្រមពេញសិទ្ធិអាចត្រូវជំនួសដោយចៅក្រមបម្រុងនៃអង្គជំនុំជម្រះនោះបានសម្រាប់តែករណីនៃបណ្ដឹងជំទាស់នោះប៉ុណ្ណោះ"។

ក្រុមប្រឹក្សាជំនុំជម្រះពិសេស ស្នើសុំឲ្យគណៈកម្មាធិការរដ្ឋបាលតុលាការ ចាត់តាំងចៅក្រមជំនួសចៅក្រម ប៉ែន ពេជ្រសាលី នៅក្នុងក្រុមប្រឹក្សាជំនុំជម្រះពិសេស ដើម្បីដោះស្រាយទៅលើបណ្ដឹងជំទាស់នានា ប្រឆាំងនឹងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ (E314/1, E314/6)។